# នីតិវិធីសាទុក្ខក្រុង

នីតិវិធីធ្វើសាទុក្ខ(ការស្នើរើសេចក្តីទុក្ខតាមច្បាប់)នេះ បានស្ថាបនាឡើងស្របទៅតាមក្រិត្យជនអាមេរិកាំងពិការ ។ វាអាចបានប្រើដោយអ្នកណាម្នាក់ដែលប្រាថ្នាធ្វើពាក្យត្អូញត្អែរ ចោទទៅលើការរើសអើង(ប្រកាន់) ដោយយោងលើភាពពិការ នៅក្នុងការអនុវត្តន៍ការងារ និងក្នុងច្បាប់នានា ឬខមានចែងស្តីពីការបំរើ សកម្មភាពផ្សេងៗ កម្មវិធី ឬអត្ថប្រយោជន៍អ្វីមួយ ដោយ <u>(name of organization) ។</u>

ការត្អូញត្អែរត្រូវតែមានជាលាយលក្ខអក្សរ និងមានពត៌មានអំពីការចោទប្រកាន់ ដូចជា  ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទនៃអ្នកត្អូញត្អែរ និងទីកន្លែង ព្រមទាំងខែថ្ងៃឆ្នាំ និងសេចក្តីរៀបរាប់នៃបញ្ហា ។ មធ្យោបាយមួយទៀតនៃការធ្វើដំអូញ ដូចជាការសំភាសន៍ផ្ទាល់ខ្លួន ឬការថតសំឡេងអ្នកត្អូញត្អែរជាដើម នឹងបានធ្វើឲ្យមានសំរាប់ជនពិការ តាមសំណូមពរ ។

ការត្អូញត្អែរគួរតែបានផ្ញើមកដោយអ្នកមានសាទុក្ខ និង/ឬ អ្នកតែងតាំងរបស់គាត់ ឲ្យបានឆាប់រហ័សបំផុតតាមលទ្ធភាព ប៉ុន្តែមិនឲ្យលើសពី 60 ថ្ងៃនៃប្រក្រតិទិន បន្ទាប់ពីបានចោទនៃការបំពានច្បាប់ឡើយ ដោយផ្ញើទៅ :

ឈ្មោះអ្នកសំរបសំរួល ADA ____________
លេខទូរស័ព្ទ ____________
TTY ____________
អាសយដ្ឋាន ____________
____________

នៅក្នុងរយៈពេល 15 ថ្ងៃនៃប្រក្រតិទិន បន្ទាប់ពីបានទទួលដំអូញ នោះអ្នកសំរបសំរួល  ADA Coordinator ______________________ នឹងជួបជាមួយអ្នកមានសាទុក្ខ ដើម្បីពិភាក្សា និងរកលទ្ធភាពដំណោះស្រាយ ។  នៅក្នុងរយៈពេល 15 ថ្ងៃនៃប្រក្រតិទិន បន្ទាប់ពីការប្រជុំពិភាក្សាគ្នារួច  ______________________ នឹងឆ្លើយតបមកវិញជាលាយលក្ខអក្សរ ហើយតាមកាលៈសមរម្យ សំបុត្រនោះនឹងមានជាទំរង់ដែលអ្នកមានសាទុក្ខអាចយល់សេចក្តីបាន ដូចជាអក្សរពុម្ពធំៗ អក្សរសំរាប់មនុស្សខ្វាក់ ឬជាខ្សែអាត់សំឡេង ជាដើម ។ ការឆ្លើយតបនេះនឹងពន្យល់ពីគោលជំហររបស់  n<u>ame of organization</u> ហើយផ្តល់ការជ្រើសរើសផ្សេងៗ សំរាប់ដំណោះស្រាយដែលមានសារសំខាន់ចំពោះសាទុក្ខ ។

បើការឆ្លើយតបពី__________________ មិនបានដោះស្រាយរឿងរ៉ាវឲ្យគាប់ចិត្តទេ នោះអ្នកមានសាទុក្ខ និង/ឬ អ្នកតែងតាំងរបស់គាត់ អាចសុំតវ៉ាការសំរេចរបស់អ្នកសំរបសំរួល ADA  ក្នុងរយៈពេល 15 ថ្ងៃបន្ទាប់ពីបានទទួលចំឡើយ ទៅគណៈនៃចាងហ្វាង ឬអ្នកតែងតាំងរបស់គាត់ ។

នៅក្នុងរយៈពេល 15 ថ្ងៃនៃប្រក្រតិទិន បន្ទាប់ពីបានទទួលសេចក្តីសុំតវ៉ា នោះគណៈនៃចាងហ្វាង ឬអ្នកតែងតាំងរបស់គាត់ នឹងជួបជាមួយអ្នកមានសាទុក្ខ ដើម្បីពិគ្រោះការត្អូញត្អែរ និងរកលទ្ធភាពដំណោះស្រាយ ។ នៅក្នុងរយៈពេល 15 ថ្ងៃនៃប្រក្រតិទិន បន្ទាប់ពីការប្រជុំគណៈនៃចាងហ្វាង ឬអ្នកតែងតាំងរបស់គាត់មក នោះគេនឹងឆ្លើយតបមកវិញជាលាយលក្ខអក្សរ ហើយតាមកាលៈសមរម្យ សំបុត្រនោះនឹងមានជាទំរង់ដែលអ្នកមានសាទុក្ខអាចយល់សេចក្តីបាន ដោយមានដំណោះស្រាយចុងក្រោយនៃការត្អូញត្អែរ ។

សេចក្តីត្អូញត្អែរជាលាយលក្ខអក្សរទាំងអស់ដែលបានទទួលដោយ ________________ រួមទាំងការសុំតវ៉ាទៅគណៈនៃចាងហ្វាង ឬអ្នកតែងតាំងរបស់គាត់ ហើយការឆ្លើយតបពីអ្នកសំរបសំរួល ADA  និងគណៈនៃចាងហ្វាង ឬពីអ្នកតែងតាំងរបស់គាត់ នឹងបានរក្សាទុកដោយ <u>(name of organization)</u> ______________________ យ៉ាងហោចណាស់ចំនួនបីឆ្នាំ ។